

សេចក្តីស្លាប់នាំឲ្យមានជីវិត



(1)

នេះគឺជាពាក្យរបស់លោក ដេ រិក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

ព្រះយេស៊ូបានមានព្រះបន្ទូលថា៖

> «ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
> បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ ១
> ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង
> អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ
> តែអ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកីយ៍នេះវិញ
> នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ»។
> [យ៉ូហាន ១២:២៤-២៥]

នោះគឺជារូបភាពដ៏ច្បាស់មួយ។ តើលោកអ្នកឃើញទេ?
អ្នកកំពុងកាន់គ្រាប់ស្រូវសាលីនៅក្នុងដៃរបស់អ្នក។

វាមានសំបករឹងបន្តិចនៅជុំវិញខ្លួនរបស់វា។ វាស្ថិតនៅក្នុងដៃរបស់អ្នក
វាគឺជារបស់អ្នក វាគឺជាជីវិតរបស់អ្នក អ្នកគ្រប់គ្រងលើវា
អ្នកធ្វើការសម្រេចចិត្ត។
អ្នកអាចសម្រេចធ្វើអ្វីតាមតែអ្នកចង់ធ្វើចំពោះវា។
អ្នកអាចកាន់វាឲ្យជាប់នៅក្នុងដៃ និងរក្សាវាទុកបាន។
ប៉ុន្តែប្រសិនបើអ្នករក្សាវាទុក ព្រះយេស៊ូមានព្រះបន្ទូលថា វានៅតែ ១
(ឯកា) ដដែល
វានឹងមិនដែលដែលមានអ្វីផ្សេងទៀតកើតចេញពីវាឡើយ។

តើមានមនុស្សឯកាប៉ុន្មាននាក់រស់នៅជុំវិញយើងក្នុងពិភពលោកសព្វ
ថ្ងៃនេះ? ពួកគេនៅឯកាដោយព្រោះតែហេតុផលនោះ។
ពួកគេកំពុងតែកាន់គ្រាប់ស្រូវសាលីដូច្នេះ។
ពួកគេមិនមានឆន្ទៈក្នុងការលែងវាឲ្យចេញពីដៃទៅនោះទេ
ហេតុដូច្នេះហើយពួកគេនៅតែមានវា វាទាំងអស់គឺជារបស់ពួកគេ ប៉ុន្តែ
អូ! វាមានភាពឯកាណាស់។

តើអ្វីទៅជាជម្រើស? ចូរលែងវាចេញទៅ ទម្លាក់វាចុះទៅ។
ចូរប្រគល់វាថ្វាយទៅព្រះជាម្ចាស់។
ចូរអនុញ្ញាតឲ្យព្រះជាម្ចាស់គ្រប់គ្រងលើវា។
ចូរមានឆន្ទៈឲ្យវាធ្លាក់ទៅលើដី ចូរឈប់សម្លឹងមើលវា
ចូរឲ្យវាកប់នៅទីនោះ ទោះបីស្ថិតនៅទីកន្លែងងងឹតក៏ដោយ។
ប្រហែលជាមនុស្សនឹងដើរជាន់លើវា
ប៉ុន្តែព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យាថា
ជីវិតថ្មីមួយនឹងកើតចេញពីវា៖

«ជីវិតដែលរស់នៅដោយមានផល
ជីវិតដែលមិនមែនសម្រាប់តែរយៈពេលខ្លីនោះទេ
ប៉ុន្តែសម្រាប់អស់កល្បជានិច្ចវិញ»។

: WD-WFTW-001-KHM
: 24 Feb 2026
: derekprince.com/km/resources

